## ៧. ការពិគ្រោះយោបល់សាធារណៈ

**២១៤.** ការពិគ្រោះយោបល់សាធារណៈ ជាមួយថ្នាក់ដឹកនាំខេត្ត ស្រុក ឃុំ ភូមិ និងប្រជាជន សហគមន៍ដែលពាក់ព័ន្ធ បានរៀបចំធ្វើឡើងនៅក្នុងដំណើរការរៀបចំរបាយការណ៍ ដើម្បីធ្វើការព្យាករណ៍អំពីហេតុប៉ះពាល់ និងផ្តល់នូវអនុសាសន៍ជាមូលដ្ឋាន។ សមាសភាពដែលបានចូលរួមពិគ្រោះយោបល់មាន: អភិបាលខេត្តកំពង់ស្ពឺ អភិបាលរងខេត្ត អគ្គលេខាធិការខេត្ត អគ្គលេខាធិការរង នាយខុទ្ទកាល័យ នាយរងខុទ្ទកាល័យ ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ខេត្ត ប្រធានមន្ទីរបរិស្ថានខេត្ត អនុប្រធានមន្ទីរកសិកម្មខេត្ត នាយរងខណ្ឌរដ្ឋបាលព្រៃឈើខេត្ត អភិបាលស្រុកឱរ៉ាល់ អភិបាលរងស្រុកឱរ៉ាល់ ការិយាល័យពាក់ព័ន្ធ និងមេឃុំ ចំនួន ២៦នាក់ កាលពីថ្ងៃទី ២៦ ខែតុលា និងថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០០៩(ឈ្មោះឧបសម្ព័ន្ធ៨-១ , និងរូបភាពឧបសម្ព័ន្ធ៨-៣) កំណត់ហេតុរបាយការណ៍ពិគ្រោះយោបល់មាននៅទំព័រ១៣៥។ ក្រុមការងារ **ហ្គ្រីន ខិនសាល់ធិនស៊ី ហ្វឹម** ក៏បានចុះទៅដល់មូលដ្ឋានឃុំសង្កែសាទប និងឃុំត្រពាំងជោ ដើម្បីធ្វើការ ពិភាក្សា និងពិគ្រោះយោលបល់ ជាមួយមេឃុំ មេភូមិ សមាជិកក្រុមប្រឹក្សា អភិវឌ្ឍន៍ភូមិ និងប្រជាជនសហគមន៍ដែលរស់នៅពាក់ព័ន្ធក្នុងតំបន់ គំរោងនៅថ្ងៃទី ២៤-៣១ ខែ តុលា ឆ្នាំ២០០៩ ដែលមក ចូលរួមចំនួន ៣១៣ នាក់ (បញ្ជីឈ្មោះ និងរូបភាព អ្នកចូលរួមមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ ៨-២ និងឧបសម្ព័ន្ធ ៨-៣)។

**របាយការណ៍សង្ខេបស្តីពីការពិគ្រោះយោបល់ជាមួយអាជ្ញាធរភូមិ ឃុំ និងប្រជាជនមូលដ្ឋាន លើការងារ វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម**

**របាយប្រជាជន**

**២១៥.** ក្រុមការងារធ្វើការសិក្សាវាយតំលៃអំពីស្ថានភាពជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក្នុងភូមិសាស្ត្រដែលក្រុមហ៊ុន **អេចអិលអេច អេគ្រីខលឈ័រ (ខេមបូឌា) ខូអិលធីឌី** បានស្នើសុំដែលមានទីតាំងស្ថិតនៅ ឃុំត្រពាំងជោ និងឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។ ឃុំត្រពាំងជោមានប្រជាជនសរុបចំនួន ១.៩៧៣គ្រួសារ ស្មើនឹង ៩.៣៧០នាក់ (ស្រី ៤.៩៥៦នាក់) ឃុំនេះមានភូមិចំនួន១០ដែលមានការពាក់ព័ន្ធទីតាំងដីក្រុមហ៊ុនស្នើសុំ។(១) ភូមិចំបក់ មានប្រជាជនរស់ នៅចំនួន ៦៨គ្រួសារ ស្មើនឹង២២៥នាក់ ក្នុងនោះស្ត្រីមាន ១៧៧នាក់ (២)ភូមិត្រាង មានប្រជាជនចំនួន ៤៦គ្រួសារ ស្មើនឹង២០៩នាក់ ក្នុងនោះស្ត្រីមាន ១១៩នាក់ (៣)ភូមិកោដូនី មានប្រជាជនចំនួន ៤៧គ្រួសារ ស្មើនឹង ១៨៨នាក់ ក្នុងនោះស្ត្រីមាន ៩៦នាក់ (៤)ភូមិពុទ្រា មានប្រជាជនចំនួន ៧០គ្រួសារ ស្មើនឹង ៣៧០នាក់ ក្នុងនោះស្ត្រីមាន ១៤០នាក់ (៥)ភូមិសំរោង មានប្រជាជនចំនួន ៤៩គ្រួសារ ស្មើនឹង ២២២នាក់ ក្នុងនោះស្ត្រីមាន ១១០នាក់ (៦)ភូមិលាក់តាន មានប្រជាជនចំនួន២៣គ្រួសារ ស្មើនឹង ១០៥នាក់ក្នុងនោះ ស្ត្រីមាន ៤៧នាក់ (៧)ភូមិក្រវៀក មានប្រជាជនចំនួន ៥៦គ្រួសារ ប្រជាជនសរុប២៦០នាក់ ស្ត្រីមាន១៣៥នាក់

Draft

(៨)ភូមិក្បាលដំរី ប្រជាជនចំនួន៦៣គ្រួសារ ប្រជាជនសរុបស្មើនឹង ២៩៥នាក់ក្នុងនោះស្ត្រី មាន១៥៧នាក់ (ស្ថិតិប្រជាជនឃុំត្រពាំងជោធ្នាំ២០០៩)។ ចំណែកឯ ឃុំសង្កែសាទបមានប្រជាជនសរុបចំនួន ១២៩៦គ្រួសារ ស្មើនឹង៦.០០៥នាក់ (ស្រី ៣.០២៤នាក់) ឃុំនេះមានភូមិចំនួន០៥ ដែលមានការពាក់ព័ន្ធទីតាំងដីក្រុមហ៊ុនស្នើសុំ។ (១) ភូមិដំបងវេញ ប្រជាជនសរុបចំនួន ១០៣គ្រួសារ ស្មើនឹង ៤៤៨នាក់ ស្ត្រីមាន២២០ នាក់ (២) ភូមិកន្ទួត ប្រជាជនសរុបចំនួន ៦៧គ្រួសារ ស្មើនឹង ៣១០នាក់ ស្ត្រីមាន១៣៩នាក់ (៣)ភូមិជំនាប់ ប្រជាជនសរុបចំនួន ៨៤គ្រួសារ ស្មើនឹង ៤០០នាក់ ស្ត្រីមាន២០១នាក់ (៤)ភូមិតាដែស មានប្រជាជនសរុប ចំនួន ១០០គ្រួសារ ស្មើនឹង ៤៧៦នាក់ ស្ត្រីមាន២៤៨នាក់ និង(៥)ភូមិក្រាំងពង្រ មានប្រជាជនសរុបចំនួន ៦៤គ្រួសារ ស្មើនឹង ២៩៧នាក់ ស្ត្រីមាន១៥៣នាក់ (ស្ថិតិប្រជាជនឃុំសង្កែសាទបឆ្នាំ២០០៩)។

**២១៦.** លំនាំនៃការតាំងទីលំនៅរបស់ប្រជាជនមានលក្ខណៈប្រមូលផ្តុំតាមភូមិក្នុងឃុំ និងការតាំងទីលំនៅតាមដងផ្លូវជាតិលេខ៥២(ទីប្រជុំជនឧដុង-ស្រុកឱរ៉ាល់) និងផ្លូវលេខ៤៤(ស្រុកច្បារមន-ស្រុកឱរ៉ាល់) ដែលជាផ្លូវគ្រួសក្រហមមិនសូវមានការលំបាកក្នុងការធ្វើ ដំណើរប៉ុន្មានទេ គ្រាន់តែមានការហុយធូលីជាពិសេសនៅរដូវប្រាំង។ ការតាំងទីលំនៅរបស់ពួកគាត់ នៅកន្លែង ខ្លះមានលក្ខណៈជាជួរបន្ទាត់ត្រឹមត្រូវ ប៉ុន្តែនៅកន្លែងខ្លះទៀតរកេតរកូតឃ្លាតឆ្ងាយៗពីគ្នា។ បើតាមការសិក្សា បង្ហាញ ថាពុំសូវមានគ្រួសារធ្វើចំណាកស្រុកពីខេត្តផ្សេងៗទៅរស់នៅតំបន់នោះទេ។ ប្រជាជនក្នុងភូមិទាំងនេះ អ្នកខ្លះមានដីស្រែចំការនៅក្បែរផ្ទះរបស់ខ្លួនក្នុងភូមិ និងប្រជាជនមួយចំនួនទៀតបានកាប់រាននិងធ្វើស្រែចំការ នៅក្នុងតំបន់ដីសម្បទានស្នើសុំរបស់ក្រុមហ៊ុន។ បើតាមការពិគ្រោះយោបល់ជាមួយអាជ្ញាធរ និងប្រជាជន មូលដ្ឋានក្នុងតំបន់បានអោយដឹងថា ពួកគាត់បានធ្វើការកាប់រានក្នុងឆ្នាំផ្សេងគ្នាក្នុងចន្លោះឆ្នាំ២០០៦-២០០៩ ដោយ អ្នកខ្លះបានកាន់កាប់និងធ្វើស្រែចំការតមក ជារៀងរាល់ឆ្នាំ ហើយអ្នកខ្លះទៀតបានធ្វើការកាប់រានបន្ទាប់មកក៏ បានទុកដីចោលក៏មាន។ ក្រៅពីនោះក៏នៅ មានប្រជាជនមួយចំនួនទៀតបន្តការកាប់រានដើម្បីយកដីធ្វើចំការ និងកាប់ឈើដុតធ្យូងធ្វើអាជីវកម្មជាបន្តបន្ទាប់ នៅក្នុងតំបន់នេះ។

**២១៧.** លទ្ធផលនៃការពិគ្រោះយោបល់ជាមួយនឹងតំណាងអោយប្រជាពលរដ្ឋមួយចំនួនបានបញ្ជាក់ថា កត្តាសំខាន់មានការខ្វះខាតគឺបណ្តាលមកពីបញ្ហាធ្វើស្រែមិនបានផល ដីស្រែរបស់គាត់បាត់បង់អស់ជីជាតិ បញ្ហាទឹកសំរាប់ធ្វើស្រែមិនគ្រប់គ្រាន់សំរាប់ទ្រទ្រង់ការលូតលាស់ និងផ្លែផ្ការបស់ស្រូវ។ បន្ថែមលើនេះទៀតជីវភាពខ្វះខាតព្រោះប្រជាជនរស់នៅក្នុងភូមិខ្លះមានដីស្រែតិចតួច មិនអាចអោយគាត់ផ្គត់ផ្គង់ជីវភាពបានល្អប្រសើរឡើយ។ ហេតុដូច្នេះហើយ ទើបធ្វើអោយពួកគាត់ចូលព្រៃដើម្បីកាប់ឈើមូល រកអុស កាប់ឫស្សី កាច់ទំពាំង ជាពិសេសមុខរបរដុតធ្យូងដែលជាប្រភពចំណូលមួយសំខាន់សំរាប់ប្រជាជននៅក្នុងតំបន់នេះ ដើម្បីផ្គត់ផ្គង់តម្រូវការក្នុងគ្រួសារបន្ថែមលើការធ្វើស្រែចំការ។

Draft

## លក្ខណៈប្រជាសាស្ត្រ

**២១៨.** ក្នុងការប្រជុំពិភាក្សាពិគ្រោះយោបល់ដែលមានការចូលរួមពីសំណាក់លោក អភិបាលរងស្រុក មេឃុំ មេភូមិ និងស្ថាប័នពាក់ពន្ធ័មួយចំនួនទៀត។ តាមការសិក្សាបានអោយដឹងថា ប្រជាជនដែលរស់នៅក្នុងតំបន់ខាងលើមានការរស់នៅជាលក្ខណៈប្រមូលផ្តុំនៅតាមភូមិក្នុងឃុំនីមួយៗ និងការតាំងទីលំនៅតាមដងផ្លូវសំខាន់ៗក្នុងតំបន់ពីផ្ទះមួយទៅមួយមានចំងាយពីគ្នាប្រមាណពី ៣០-៥០ម៉ែត្រក៏មាន ដោយសារដីលំនៅដ្ឋានរបស់គ្រួសារភាគច្រើនមានទំហំធំ មានអ្នកខ្លះទុកដីទំនេរចោលដែលធ្វើអោយការការសង់ផ្ទះមានលក្ខណៈរង្វើល។ ចំពោះទំនៀមទំលាប់ប្រពៃណីនៃការរស់នៅរបស់ប្រជាជនភាគច្រើនក្នុងឃុំត្រពាំងជោ និងឃុំសង្កែសាទប មានលក្ខណៈប្រហាក់ប្រហែលគ្នា។ ប្រជាជនភាគច្រើនប្រសិនបើពួកគាត់ធ្វើស្រែតែមួយមុខពួកគាត់មិនអាចដោះស្រាយ និងផ្គត់ផ្គង់ជីវភាពបានឡើយ ដូច្នេះការធ្វើចំការ និងចិញ្ចឹមសត្វ ពិសេសគោ-ក្របី និងការដុតធ្យូងលក់ក៏ជាមុខ របរយ៉ាងសំខាន់ដែរក្នុងការទ្រទ្រង់ជីវភាពគ្រួសារបន្ថែមទៀត។ នៅក្នុងនោះមានគ្រួសារខ្លះចិញ្ចឹមសត្វ ជាលក្ខណៈគ្រួសារ ដូចជាៈ គោ ក្របី ជ្រូក មាន់ ទា ជាដើមដើម្បីជាប្រភពចំណូលបន្ថែម។ ទន្ទឹមនឹងនេះ ប្រជាពលរដ្ឋក្នុងឃុំបានដាំដំណាំហូបផ្លែ និងបន្លែបង្កាចំរុះផ្សេងៗទៀតនៅតាមលំនៅដ្ឋានក្នុងភូមិ និងដាំនៅ តាមដីចំការឬក្បាលស្រែ ដូចជាៈ ចេក អំពៅ ចេក ដូង ខ្នុរ និងស្វាយជាដើម។

**២១៩.** ទំនៀមទំលាប់ និងប្រពៃណីនៃការរស់នៅរបស់ប្រជាជនក្នុងភូមិនៃសង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ ដែលពាក់ព័ន្ធនឹងទីតាំងស្នើសុំដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន មានលក្ខណៈប្រហាក់ប្រហែលគ្នា។ ប្រជាជនក្នុងភូមិទាំងអស់ប្រសិនបើពួកគាត់ធ្វើស្រែតែមួយមុខ ពួកគាត់ មិនអាចដោះស្រាយនិងផ្គត់ផ្គង់ជីវភាពបានឡើយ។ ចំពោះអ្នកដែលរស់នៅតាមតំបន់ព្រៃមានលទ្ធភាពទទួលបានដីច្រើនជាងប្រជាជនដែលរស់នៅតាមតំបន់ផ្សេងៗ ព្រោះតែពួកគេរានដីព្រៃបន្ថែម។ ហេតុដូចនេះហើយទើបប្រជាជនភាគច្រើនបានបបួលគ្នាមកកាប់រានដីព្រៃសំរាប់ធ្វើស្រែ ចំការ។ ក្រៅពីនេះពួកគាត់បានដាំដំណាំ ផ្សេងៗទៀតដូចជា ឪឡឹក អំពៅ ចេក ដំឡូង និងស្វាយជាដើម។

**២២០.** ចំពោះជនបង្គោល ឬអ្នកដើរតួនាទីសំខាន់នៅក្នុងការទ្រទ្រង់ជីវភាពគ្រួសារនៅតំបន់នេះ យើងសង្កេតឃើញថាភាគច្រើនជាបុរស។ ចំណែកលទ្ធភាពទទួលការអប់រំរបស់មេគ្រួសារនៅក្នុងតំបន់នេះវិញមានកំរិតបើប្រៀបធៀបនឹងលទ្ធភាពដែលមេគ្រួសារនៅតាមទីក្រុង និងតាមទីប្រជុំជនធំៗបានទទួល។ នាពេលបច្ចុប្បន្នវិស័យអប់រំមានការរីកចំរើននៅក្នុងតំបន់ ហើយកុមារនៅទីនេះក៏បានចូលសាលាគ្រប់គ្នាដែរ ប៉ុន្តែនៅមានជួបបញ្ហាមួយចំនួន សាលាស្ថិតនៅឆ្ងាយពីភូមិខ្លះសំរាប់សិស្សដែលត្រូវបន្តទៅរៀននៅថ្នាក់អនុវិទ្យាល័យ ឬត្រូវបន្តទៅវិទ្យាល័យ ដោយត្រូវធ្វើដំណើរនៅទីរួមស្រុក។

Draft

**២២១.** ប្រជាជនដែលរស់នៅក្បែរតំបន់ស្នើសុំដីសម្បទាន ភាគច្រើនជាជនជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ ដូច្នេះហើយទំនៀមទំលាប់នៃការរស់នៅរបស់ពួកគាត់មិនមានលក្ខណៈខុសគ្នា ពីប្រជាជនតាមទីប្រជុំជន ផ្សេងៗនៅ ក្នុងប្រទេសកម្ពុជាដែរ។ ឧទាហរណ៍ដូចជា ក្នុងពិធីរៀបអាពាហ៍ពិពាហ៍ គឺធ្វើតាមប្រពៃណីខ្មែរ ដោយការតុប តែងសំអិតសំអាងកូនកំលោះ កូនក្រមុំ ការប្រគុំភ្លេងខ្មែរ ពិធីកាត់សក់ ពិធីហែរជំនួន កាត់ខាន់ស្លា បាចផ្កាស្លា សំពះផ្ទឹម ចងដៃ និងមានការអញ្ជើញចូលរួមពីភ្ញៀវអបអរសាទរ ជូនពរជ័យក្នុងពិធីមង្គលការនេះ។

**ស្ថានភាពផ្ទះសម្បែង និងទ្រព្យសម្បត្តិរបស់គ្រួសារ**

**២២២.** តាមលទ្ធផលនៃការសិក្សា ក៏ដូចជាការអង្កេតផ្ទាល់ឃើញថាប្រជាជននៅក្នុងភូមិពាក់ព័ន្ធមានជីវភាពរស់នៅជាមធ្យម និងលទ្ធភាពសង់លំនៅដ្ឋានមានស្ថានភាពប្រហាក់ប្រហែលគ្នា។ ដោយសារតែការរស់នៅរបស់ប្រជាជននៅភូមិទាំងអស់នោះស្ថិតនៅតំបន់ដែលធ្លាប់សំបូរទៅដោយឈើដែលមានសក្តានុពល អាចអោយពួកគាត់ខ្លះមានលទ្ធភាពក្នុងការទាញយកឈើ និងសន្សំរក្សាទុកដើម្បីសាងសង់លំនៅដ្ឋានបានសមរម្យបើយើងប្រៀបធៀបនឹងលំនៅស្ថានជនបទភាគច្រើននៅក្នុងប្រទេសកម្ពុជាផ្សេងទៀត ដែលប្រជាជនមិនបានទទួលផលពីប្រភពធនធានធម្មជាតិទាំងនោះ។ ថ្វីត្បិតតែការសាងសង់ផ្ទះរបស់ពួកគាត់ធ្វើទៅតាមលទ្ធភាព និងចំនួនសមាជិកនៃគ្រួសារនិមួយៗក៏ដោយភាគច្រើនផ្ទះរបស់ពួកគាត់ធ្វើអំពីឈើប្រក់ក្បឿង (នៅតាមដងផ្លូវក្នុងឃុំ) ឬសង់អំពីឈើប្រក់សង្ក័សី/ស៊ីប្រូ និងមួយចំនួនទៀតធ្វើអំពីឈើប្រក់ស្លឹក។

Draft

**២២៣.** តាមការសាកសួរបានបង្ហាញថា គោ ក្របី រទេះ នង្គ័ល និងរនាស់ នៅតែមានតួនាទីយ៉ាងសំខាន់ក្នុងវិស័យកសិកម្មដែលជាកត្តាដ៏ចម្បងសម្រាប់ផ្គត់ផ្គង់ជីវភាពរស់នៅ របស់ប្រជាពលរដ្ឋនៅតាមតំបន់ជនបទ។ ការភ្ជួររាស់ភាគច្រើនគឺពឹងផ្អែកទៅលើគោក្របី ហើយគ្រួសារមួយចំនួនទៀតមានលទ្ធភាពទិញគោយន្ត ដើម្បីប្រើប្រាស់ជំនួសអោយការប្រើប្រាស់គោក្របី ប៉ុន្តែមានប្រជាជនទីទ័លក្រ មួយចំនួនដែលពុំមានគោ ក្របី បានប្រើប្រាស់កំលាំងផ្ទាល់ខ្លួនកាប់គាស់ដោយចបកាប់ ក្នុងការធ្វើស្រែចំការ។ ផលដែលបានក្នុងមួយឆ្នាំៗគឺទុកសម្រាប់តែហូបក្នុងគ្រួសារប៉ុណ្ណោះ មានមួយចំនួនតូចទិន្នផលបានមកលើសតំរូវការក្នុងគ្រួសារ និងអាចលក់ដូរជារបស់របរផ្សេងទៀតសំរាប់ការប្រើប្រាស់ប្រចាំថ្ងៃ។ ចំពោះគ្រួសារដែលមានកូនច្រើន ឬគ្រួសារផ្សេងទៀតដែលមានជីវភាពយ៉ាប់យឺន ហើយផលស្រូវដែលទទួលបានតិចតួចហូបមិនគ្រប់គ្រាន់ ម្ល៉ោះហើយជូនកាលគាត់មានការខ្វះខាតត្រូវទៅខ្ចីបុលតាមរយៈអង្គការអភិវឌ្ឍន៍ ឬប្រជាជនក្នុងភូមិមកបង្គ្រប់បន្ថែម។ បច្ចុប្បន្នមានអង្គការផ្សេងៗបានជ្រើសរើស និងលើកគំរោងរបស់ខ្លួនដើម្បីអភិវឌ្ឍន៍សហគមន៍ជនបទនេះតាមរយៈផែនការសកម្មភាពជាច្រើនក្នុងគោលបំណងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជន។ ក្នុងចំណោមអង្គការទាំងនោះ LWF ជាអង្គការអន្តរជាតិមួយ ដែលបានចូលរួមអភិវឌ្ឍន៍សហគមន៍ជនបទមួយនេះយ៉ាងច្រើនដែលរួមមាន

ការផ្តល់អណ្តូងស្នប់ ការជួយលើវិស័យហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋាន ការបណ្តុះបណ្តាលនូវបច្ចេកទេសចិញ្ចឹមសត្វ ដាំដំណាំ និងការបង្កើតអោយមានធនាគារភូមិសំរាប់ផ្តល់ប្រាក់កម្ចីក្នុងអត្រាការប្រាក់ទាប។

**២២៤.** ក្រៅពីការចិញ្ចឹមគោ-ក្របីប្រើប្រាស់ជាកំលាំងអូសទាញ ប្រជាជននៅមានចិញ្ចឹមសត្វជាលក្ខណៈគ្រួសារសម្រាប់ទ្រទ្រង់ជីវភាពគ្រួសាររបស់ពួកគាត់បន្ថែមទៀត ដូចជាគ្រួសារខ្លះមានចិញ្ចឹមជ្រូកពី១-២ក្បាល គ្រួសារខ្លះមានជ្រូក៥ក្បាល ចិញ្ចឹមមាន់ ៥-១០ក្បាលគ្រួសារខ្លះ មានមាន់ ២០-៤០ក្បាល គ្រួសារខ្លះចិញ្ចឹមគោពី១-៥ក្បាល គ្រួសារខ្លះចិញ្ចឹមគោជាទ្រង់ទ្រាយមធ្យមពី ៥-២០ក្បាល។ ក្រៅពីការធ្វើស្រែចំការ និងការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ ប្រជាជនមួយចំនួនបានធ្វើឡធ្យូង ដែលជាប្រជាប្រភពចំណូលសំខាន់មួយទៀតសំរាប់ប្រជាជននៅតំបន់នេះដោយបានកាប់ឈើក្នុងព្រៃពីតំបន់ក្បែរខាងដើម្បីដុតធ្វើធ្យូង ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារបន្ថែម និងទុកសម្រាប់ដោះស្រាយនៅរដូវវស្សា។

**២២៥.** ចំពោះការប្រើប្រាស់និងការកាន់កាប់ដីធ្លីរបស់ពួកគាត់វិញគឺពុំទាន់មានបង្កាន់ដៃកាន់កាប់ ឬបណ្ណ័កម្មសិទ្ធត្រឹមត្រូវនៅឡើយទេ ហើយដីលំនៅដ្ឋានដែលពួកគាត់មានជាមធ្យមក្នុងមួយគ្រួសារគឺ ៦០០-១២០០ម$^{២}$។ តាមការជួបពិគ្រោះជាមួយប្រជាជននៅតំបន់នោះបានអោយដឹងថា ការធ្វើស្រែរបស់ពួកគាត់គឺពឹងផ្អែកលើទឹកភ្លៀងទាំងស្រុង ជាក់ស្តែងតាមការអង្កេតរបស់ក្រុមការងារ ស្រូវនៅក្នុងស្រែមួយចំនួនបានទទួលរងនូវការខ្វះទឹក ដីមានលក្ខណៈស្ងួត និងបែកក្រហែងដោយកន្លែង។ ក្នុងការងារបង្កបង្កើនផល ពួកគាត់មិនសូវប្រើប្រាស់ជីគីមីទេ ដោយសារវាមានតំលៃថ្លៃ ប៉ុន្តែពួកគាត់បានប្រើជីធម្មជាតិជំនួសវិញ មានគ្រួសារប្រមាណ១០%ប៉ុណ្ណោះដែលបានប្រើប្រាស់ជីគីមី។

**សេវាសាធារណៈ**

**២២៦.** គួរបញ្ជាក់ថា លទ្ធភាពនៃការប្រើប្រាស់សេវាសាធារណៈ (គមនាគមន៏ ការផ្គត់ផ្គង់ទឹកស្អាត អគ្គិសនី អប់រំ និងសុខាភិបាល) នៅក្នុងតំបន់ដែលពាក់ព័ន្ធនឹងទីតាំងស្នើសុំដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនស្ថិតនៅក្រោមបន្ទាត់នៃតំរូវការ។ ផ្លូវគមនាគមន៏នៅក្នុងតំបន់នេះមិនសូវជួបការលំបាកទេ ពីព្រោះផ្លូវសំខាន់ៗសំរាប់ធ្វើដំណើរ និងដឹកជញ្ជូនភាគច្រើនជាផ្លូវក្រាលក្រួសក្រហមគ្រាន់តែមានសភាពហុយបន្តិចនៅរដូវប្រាំង និងមានភាពរអិល និងទឹកដក់ដោយកន្លែងនៅរដូវវស្សាដោយសារការដឹកជញ្ជូនលើសកំរិត។ សេវាសុខាភិបាលក៏នៅតែជួបការលំបាកសំរាប់ធានាបាននូវការផ្តល់ជូននូវការពិគ្រោះព្យាបាលជូនប្រជាជនក្នុងមូលដ្ឋាន ដោយសារមានភូមិខ្លះនៅឆ្ងាយពីមណ្ឌលសុខភាពដែលធ្វើអោយមានការលំបាកក្នុងការបញ្ជូនអ្នកជំងឺពេលឈឺថ្កាត់ម្តងៗ។ វិស័យអប់រំនៅក្នុងតំបន់នេះក៏ពុំទាន់មានលក្ខណៈពេញលេញនៅឡើយទេ ដោយសារសិស្សត្រូវបន្តការសិក្សានៅ អនុវិទ្យាល័យ ឬវិទ្យាល័យ នៅជួបការលំបាកក្នុងការធ្វើដំណើរឆ្ងាយពីលំនៅដ្ឋាន។ ភាពខ្វះខាតនៃសេវា

សាធារណៈទាំងអស់នេះបានបង្កការលំបាកក្នុងការរស់នៅមួយដែលយើងគួរយកចិត្តទុកដាក់ ចំពោះពួកគាត់នៅទីនោះ ហើយវាក៏ជាបន្ទុកសម្រាប់រាជរដ្ឋាភិបាលផងដែរ។

**២២៧.** ចំពោះលទ្ធភាពនៃការប្រើប្រាស់ទឹកស្អាតនៅក្នុងតំបន់នេះឃើញថា ពុំទាន់បំពេញតំរូវការគ្រប់គ្រាន់នៅឡើយទេបើប្រៀបធៀបជាមួយនឹងប្រជាជនដែលនៅទីប្រជុំជន។ ជាក់ស្តែងនៅក្នុងភូមិនីមួយៗត្រូវបានឧបត្ថម្ភអណ្តូងស្នប់សំរាប់ប្រើប្រាស់ដោយក្នុងមួយអណ្តូងត្រូវប្រើ ១០-១៥គ្រួសារឯណោះដោយពួកគាត់ ជួនកាលត្រូវខាតពេលវេលាដើម្បីធ្វើការងារផ្សេងទៀត ដែលត្រូវរង់ចាំគ្នាជាបន្តបន្ទាប់ដើម្បីបានទឹកប្រើប្រាស់ ឬផ្ទះនៅឆ្ងាយពីទីតាំងអណ្តូងដែលត្រូវដងទឹក។ ក្រៅពីនោះមានគ្រួសារខ្លះបានប្រើប្រាស់ទឹកបានពីអណ្តូងជីកដៃ និងសំរាប់គ្រួសារមានជីវភាពគ្រាន់បើបានទិញពាងទឹកដើម្បីត្រងទឹកភ្លៀងទុកសំរាប់ប្រើប្រាស់។ គួររំលឹកថាដើមឡើយការប្រើប្រាស់ទឹកនៅក្នុងតំបន់នេះមានការលំបាកខ្លាំងដោយត្រូវប្រើប្រាស់ទឹក អូរ ត្រពាំង បឹងផ្សេងៗនៅក្នុងតំបន់ដែលគ្មានអនាម័យ និងប៉ះពាល់ដល់សុខភាពយ៉ាងធ្ងន់ធ្ងរ ប៉ុន្តែក្រោយពីមានវត្តមានអង្គការ ឡើ្យដែលបានផ្តល់អណ្តូងស្នប់ជាបន្តបន្ទាប់តាមរយៈគំរោងផ្សេងៗ បានធ្វើអោយប្រជាជនមានការធូរស្រាលមួយកំរិត និងមានភាពល្អប្រសើរជាងមុន។

**២២៨.** ប្រជាជននៅក្នុងឃុំត្រពាំងជោ និងឃុំសង្កែសាទប ស្រុកឱរ៉ាល់ទាំងមូលពុំទាន់ទទួលបាន ការផ្គត់ផ្គង់អគ្គិសនី ជាមូលដ្ឋាននៅឡើយទេ។ ប្រជាជនភាគច្រើនមានលទ្ធភាពប្រើប្រាស់ត្រឹមភ្លើងអំពូលអាគុយ និងចង្កៀងប្រេងកាតដុតបំភ្លឺ សំរាប់គ្រួសារដែលមានជីវភាពធូរធារមានលទ្ធភាពប្រើប្រាស់ម៉ាស៊ីនភ្លើង ជាលក្ខណៈគ្រួសារ (មានតិចតួច)។ ដូច្នេះ ពួកគាត់ទទួលព័ត៌មាន ឬដំណឹងផ្សេងៗតាមរយៈវិទ្យុ និងទូរទស្សន៍ ក៏មិនបានគ្រប់គ្រាន់ដែរ។ ចំណែកការចំអិនអាហារវិញ គឺពួកគាត់ប្រើឲ្យស និងអុសដែលអាចរកបានពីព្រៃចំងាយ ប្រមាណ ១-៣ គ.ម ពីលំនៅដ្ឋានដែលមិនត្រឹមតែសំរាប់ប្រើប្រាស់ក្នុងគ្រួសារប៉ុណ្ណោះទេ ថែមទាំងអាចលក់ យកកំរៃបន្ថែមបានទៀតផង។

**២២៩.** ចំណែកវិស័យអប់រំសិក្សាធិការវិញ នៅក្នុងឃុំដែលមានការពាក់ព័ន្ធនឹងដីស្នើសុំសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ក្រុមការងារយើងបានសាកសួរព័ត៌មានពីអាជ្ញាធរមូលដ្ឋាន និងប្រជាជននៅទីនោះបានអោយដឹងថាការសិក្សារបស់សិស្សនៅកំរិតបឋមសិក្សាមិនសូវជួបការលំបាកប៉ុន្មានទេ។ ចំពោះសិស្សានុសិស្សដែលត្រូវបន្តការសិក្សានៅកំរិតអនុវិទ្យាល័យ និងវិទ្យាល័យ មានការលំបាកសំរាប់សិស្សដែលនៅឆ្ងាយ គួបផ្សំនឹងកង្វះខាតមធ្យោបាយធ្វើដំណើរផងនោះ ជាមូលហេតុបណ្តាលអោយសិស្សមួយចំនួនបង្ខំចិត្តបោះបង់ការសិក្សាទាំងភាពសោកស្តាយ។

Draft

**២៣០.** វិស័យសុខាភិបាលនៅក្នុងតំបន់នេះមិនទាន់មានលក្ខណៈល្អប្រសើរ និងផ្តល់លទ្ធភាពដល់ប្រជាជនទទួលសេវាទាំងនេះបានពេញលេញនៅឡើយទេ។ ជាក់ស្តែងនៅក្នុងឃុំត្រពាំងជោ មិនមានមណ្ឌលសុខភាពសំរាប់ឃុំទេតែមានប៉ុស្តិ៍សុខភាព ចំណែកឃុំសង្កែសាទបមានមណ្ឌលសុខភាពសំរាប់បំរើការក្នុងស្រុកទាំងមូល ពេលមានសមាជិកគ្រួសារណាម្នាក់មានជំងឺនឹងត្រូវបញ្ជូនទៅពិនិត្យព្យាបាលនៅមណ្ឌលសុខភាព ស្រុកដែលមានចំងាយប្រមាណ ២០-២០,៧៨ គីឡូម៉ែត្រ(ឃុំត្រពាំងជោ-ស្រុកឱរ៉ាល់)។ បើអ្នកជំងឺមានសភាពធ្ងន់ធ្ងរត្រូវបញ្ជូនទៅព្យាបាល នៅមន្ទីរពេទ្យខេត្តកំពង់ស្ពឺ ឬទៅភ្នំពេញតែម្តង។

**ប្រភពធនធានធម្មជាតិ និងលទ្ធភាពនៃការទទួលយកធនធានធម្មជាតិ**

**២៣១.** ធនធានធម្មជាតិមានព្រៃឈើ ហើយចំពោះការទាញយកប្រយោជន៍ពីធនធានធម្មជាតិទាំងនោះមានដូចជាៈ អារឈើមូល វាយផ្តៅ ដងជ័រទឹក បេះផ្សិតឈើ កាប់ឫស្សី រកទំពាំង ការបរបាញ់សត្វ។ តាមរយៈការសិក្សាយើងបានឃើញថា គុណភាពព្រៃឈើមានការធ្លាក់ចុះយ៉ាងខ្លាំងក្នុងរយៈពេល២ទសវត្សចុង ក្រោយនេះហើយបច្ចុប្បន្ននេះពុំមានឈើប្រណិត១សំរាប់ធ្វើពាណិជ្ជកម្មទៀតទេនៅក្នុងដីសម្បទាននោះ។

**ប្រភពចំណូលសំខាន់របស់គ្រួសារ**

**២៣២.** ជីវភាពរស់នៅរបស់ប្រជាជនរស់នៅក្នុងឃុំត្រពាំងជោ និងឃុំសង្កែសាទប គឺអាស្រ័យការធ្វើស្រែចំការនិងចិញ្ចឹមសត្វ (រយៈពេល៣-៤ឆ្នាំកន្លងមកនេះចំណូលសំខាន់គឺអាជីវកម្មឡដុតធ្យូង មួយគ្រួសារអាចមានឡធ្យូងចាប់ពី២-៤ឡ ដែលមួយឡ១ប្រើប្រាស់អុសចាប់ពី៥ដឹក រហូតដល់១០ដឹកឯណោះ) ។ ហើយនៅឆ្នាំ២០០៧-២០០៨ស្រូវ របស់ពួកគាត់ទទួលបានផលមិនគ្រប់គ្រាន់ដោយសារកត្តាអាកាសធាតុ រាំងស្ងួត សត្វល្អិតបំផ្លាញ និងគួបផ្សំជា មួយកត្តាចំណេះដឹងថែមទៀតផង។ ដូច្នេះដើម្បីបង្គ្រប់ភាពខ្វះខាតក្នុងជីវភាពគ្រួសារពួកគាត់បាននាំគ្នាកាប់ ទន្ទ្រានដីព្រៃសម្រាប់ធ្វើចំការ និងដាំដំណាំផ្សេង១ដូចជាៈ ស្រូវ ចេក ពោត ដំឡូង សណ្តែក អំពៅ ស្វាយ និងខ្នុរជាដើម។ លើសពីនេះទៅទៀតពួកគាត់បានចូលព្រៃដើម្បីកាប់ ឈើមូល កូនឈើ ឈើក្រាក់ អុសដុតធ្យូង រកទំពាំង បេះផ្សិត និងកាប់ឫស្សីជាដើម។

**២៣៣.** ដីស្រែចំការជាមធ្យមក្នុងមួយគ្រួសារមាន ១-៥ហិកតា សំរាប់ដាំដុះ និងបង្កបង្កើនផលដោយពួកគាត់ដាំដំណាំស្រូវជារៀងរាល់ឆ្នាំក្នុងកំរិតទិន្នផលជាមធ្យម១,៥តោន/ហិកតា(ស្រូវ១២០០-១៥០០រៀល/គ.ក)។ ក្រៅពីរបរធ្វើស្រែចំការមានគ្រួសារខ្លះមានចិញ្ចឹមជ្រូកពី ១-២ក្បាល គ្រួសារខ្លះមានជ្រូក៥ក្បាល(ជ្រូករស់១ក្បាលលក់បាន២០-៤០ម៉ឺនរៀល) ចិញ្ចឹមមាន់ ៥-១០ក្បាលគ្រួសារខ្លះ មានមាន់២០-៤០ក្បាល(មាន់លក់បាន១៤០០០-១៥០០០រៀល/គ.ក) គ្រួសារខ្លះចិញ្ចឹមគោពី១-៥ក្បាល គ្រួសារខ្លះចិញ្ចឹមគោទ្រង់ទ្រាយមធ្យម ពី៥-២០ក្បាល (គោ១ក្បាល ៥០ម៉ឺន-២លានរៀល)។ លើសពីនោះទៀតមានប្រជាជនមួយចំនួនបានធ្វើឡធ្យូង

ដែលជាប្រភពចំណូលសំខាន់មួយទៀត សំរាប់ប្រជាជននៅតំបន់នេះដោយបានកាប់ឈើក្នុងព្រៃពីតំបន់ក្បែរខាងដើម្បីដុតធ្វើធ្យូង (កំរៃដែលអាចរកបានពីការដុតធ្យូងក្នុងរយៈពេល១ខែពី ២០-៣០ម៉ឺនរៀល/ឡ) ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារបន្ថែម ប៉ុន្តែបច្ចុប្បន្នសកម្មភាពដុតធ្យូងមានការធ្លាក់ចុះដោយសារស្ថានភាពព្រៃនៅក្នុងតំបន់នេះមិនមានឈើច្រើនដែលអាចអោយពួកគាត់ផ្គត់ផ្គង់ឡទាំងនោះបានទៀតទេ ជាក់ស្តែងក្រុមការងារបានសង្កេតឃើញឡធ្យូងមួយចំនួនត្រូវបានគេបោះបង់ចោល ។

**វិបត្តិដែលធ្វើអោយលទ្ធភាពទិញជូវរបស់គ្រួសារធ្លាក់ចុះ**

**២៣៤.** នៅក្នុងសហគមន៍ដែលក្រុមការងារបានចុះធ្វើការអង្កេត បានបង្ហាញអោយឃើញអំពីរូបភាពនៃវិបត្តិដែលកើតមានឡើងនៅក្នុងសហគមន៍ទាំងនោះមានដូចជា :

- ❖ ពួកគាត់មានដីសម្រាប់បង្កបង្កើនផល តែខ្វះចំណេះដឹង និងបច្ចេកទេសក្នុងការដាំដុះ និងថែទាំ ។ ដូច្នេះដើម្បីបង្គ្រប់សេចក្តីត្រូវការ ពួកគាត់ចូលព្រៃរកអនុផលព្រៃឈើបង្គ្រប់ជីវភាពបន្ថែម ។
- ❖ ការធ្វើស្រែចំការតាមបែបបុរាណគឺធ្វើស្រែប្រវាស់មេឃ ជាហេតុដែលធ្វើអោយប្រជាពលរដ្ឋក្នុងសហគមន៍ទាំងនោះទទួលបានផល មិនឆ្លើយតបទៅនឹងតំរូវការនិងការខិតខំប្រឹងប្រែងដែលធ្វើអោយគ្រួសារខ្លះមិនគ្រប់គ្រាន់ខ្វះស្បៀងក្នុងរយៈពេល ២-៣ខែ ។
- ❖ ដីស្រែធ្វើតែស្រូវមួយមុខមិនបានផ្លាស់ប្តូរមុខដំណាំដែលទាញយកផលតែពីដីហើយមិនបានផ្តល់ជីជាតិទៅឱ្យដីវិញទាល់តែសោះធ្វើឱ្យដីកាន់តែរេចរឹលទៅៗ ។
- ❖ ចំណែកឯបញ្ហាសុខភាពក៏នៅតែជាបញ្ហាចោទមួយដ៏សំខាន់ ដែលប្រជាជននៅតំបន់នេះកំពុងតែប្រឈមមុខដោយសារសេវាសុខភាពមិនទាន់គ្រប់គ្រាន់នៅឡើយ ។ ក្នុងករណីមានសមាជិកណាម្នាក់ធ្លាក់ខ្លួនឈឺត្រូវបញ្ជូនទៅមណ្ឌលសុខភាព នៅពេលស្ថានភាពជំងឺធ្ងន់ធ្ងរមិនអាចព្យាបាលនៅក្នុងមូលដ្ឋានបាន ទើបតម្រូវអោយពួកគាត់បង្ខំចិត្តបញ្ជូនទៅមន្ទីរពេទ្យខេត្ត ឬទីក្រុងហើយទន្ទឹមនឹងនោះដែរដើម្បីដោះស្រាយរាល់វិបត្តិទាំងនោះ ពួកគាត់បានប្រើគ្រប់មធ្យោបាយទាំងអស់ទៅតាមលទ្ធភាពដែលអាចធ្វើទៅបានដូចជាៈ ខ្ចីបុលស្រូវពីអ្នកដទៃ ដាក់ស្រែបញ្ចាំ ចងការប្រាក់ លក់ស្រូវអង្ករ លក់គោ ក្របីជាដើម ។ ទាំងនេះជាយុទ្ធសាស្ត្រមួយដើម្បី ដោះទាល់នៅពេលដែលជួបប្រទះនូវវិបត្តិសេដ្ឋកិច្ចក្នុងគ្រួសារ ។

Draft

**ហេតុប៉ះពាល់នៃការអនុវត្តគំរោងកសិ-ឧស្សាហកម្ម ទៅលើជីវភាពរស់នៅរបស់សហគមន៍ និងការទទួលយករបស់មូលដ្ឋានចំពោះគំរោងអភិវឌ្ឍន៍ :**

យោងលើលទ្ធផលនៃការសិក្សាពិគ្រោះយោបល់ជាមួយថ្នាក់ដឹកនាំខេត្ត ស្រុក មន្ទីរ ឃុំ ភូមិ ដែលពាក់ព័ន្ធបានបង្ហាញថាៈ

**២៣៥.** ថ្នាក់ដឹកនាំខេត្ត ស្រុក មន្ទីរ/ស្ថាប័នពាក់ព័ន្ធៈ ក្នុងករណីដែលរាជរដ្ឋាភិបាលធ្វើការប្រទានសិទ្ធិអោយក្រុមហ៊ុនធ្វើការវិនិយោគលើដំណាំកសិឧស្សាហកម្ម នោះនឹងនាំមកនូវផលប្រយោជន៍ពហុវិជ្ជមានច្រើនយ៉ាងទាំងលើវិស័យសេដ្ឋកិច្ច សង្គម និងបរិស្ថាន។ ទោះបីជាពួកគាត់មិនអាចផ្តល់ព័តិមានលំអិតពាក់ព័ន្ធនិងផលប្រយោជន៍ទាំងនេះក្តី តែពួកគាត់បានសំដែងសេចក្តីបារម្ភអំពីការធ្លាក់ចុះនិងបន្តបាត់បង់ធនធានព្រៃឈើដោយសារការទន្ទ្រានយកដីធ្លីធ្វើកម្មសិទ្ធិតាមគ្រប់រូបភាពតូចធំ និងសកម្មភាពប្រមូលផលព្រៃឈើដែលបាននិងកំពុងបន្តយ៉ាងអនាធិបតេយ្យក្នុងរូបភាពឆ្នក់លួចលាក់។

**២៣៦.** ជាការពិតណាស់ដែលថាការអភិវឌ្ឍន៍តែងតែមានចំនុចអវិជ្ជមាន និងការខ្វែងគំនិតគ្នារវាងវិនិយោគិនជាមួយអាជ្ញាធរនិងសហគមន៍មូលដ្ឋាន ឬរវាងវិនិយោគិននិងអាជ្ញាធរ ជាមួយអង្គការសង្គមស៊ីវិល និងសហគមន៍មូលដ្ឋាន ទៅលើផលប្រយោជន៍រួមមួយដែលទាំងអស់គ្នាមានសិទ្ធិក្នុងការទទួលបាន ប៉ុន្តែទិសដៅនិងគោលបំណងរួមរបស់ពួកយើង គឺសំដៅធ្វើយ៉ាងណាដើម្បីទទួលបាននូវការអភិវឌ្ឍន៍នៅកម្ពុជាមួយដែលធានាបាននូវកំណើននិងការអភិវឌ្ឍន៍ ជាពិសេសសម្រាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជាយុទ្ធសាស្ត្រ ដែលក្នុងនោះត្រូវពង្រឹងនិងលើកកំពស់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន ក្នុងក្របខ័ណ្ឌមួយដែលមានលក្ខណៈអាចទទួលយកបានទាំងផ្នែកសង្គម-បរិស្ថាន និងមានប្រសិទ្ធិភាពសេដ្ឋកិច្ច។

**២៣៧.** ជាដំបូង ដោយសារប្រជាពលរដ្ឋមិនទាន់បានយល់ច្បាស់ពីផលប្រយោជន៍ដែលនឹងត្រូវទទួលបានមកវិញពីការដែលរាជរដ្ឋាភិបាលប្រទានដីសម្បទានសេដ្ឋកិច្ចដល់ក្រុមហ៊ុន ដើម្បីក្រុមហ៊ុនចូលមកធ្វើការវិនិយោគ ពួកគាត់មានការចង្អៀតចង្អល់ជាខ្លាំង ពីព្រោះពួកគាត់បារម្ភណ៍ខ្លាចក្រែងក្រុមហ៊ុននោះមកយកដីរបស់ពួកគាត់ ដោយកន្លងមកមានក្រុមហ៊ុនមួយមិនបានអនុវត្តន៍សមស្របទៅតាមគោលការណ៍នៃដីសម្បទានសេដ្ឋកិច្ច ធ្វើឱ្យប្រជាពលរដ្ឋមានការថ្នាំងថ្នាក់ ហើយយល់ថាការអភិវឌ្ឍន៍របស់ក្រុមហ៊ុនមិនបានធ្វើឱ្យពួកគាត់ទទួលបានផលប្រយោជន៍អ្វីសោះ ក្រៅពីពួកគាត់ត្រូវបាត់បង់ដីដែលជាកេរ្តិ៍ដំណែលរបស់ខ្លួនទៀតផង។ ដូចនេះ ពួកគាត់បានស្រុះគំនិតគ្នាថាមិនទទួលយកជាដាច់ខាតចំពោះគំរោងផ្តល់ដីសម្បទានដល់ក្រុមហ៊ុនណាមួយឡើយ ដោយពួកគាត់បានលើកឡើងថា ជួនកាលនៅឆ្នាំខ្លះពួកគាត់ខ្វះស្បៀងរហូតដល់ទៅ៥ខែ ដើម្បីបំពេញការខ្វះខាតគឺពួកគាត់អាចចូលព្រៃទាញយកផលពីអនុផលព្រៃឈើបាន ដូចជាកាប់ឈើមូល ជងជ័រទឹក ជ័រចុង កាប់ស្បៀ

Draft

ទំពាំង បេះផ្សិត បេះផ្កាក្រឡើតចក បេះផ្លែឈើ កាប់ស្លឹក រកឃ្មុំ នេសាទត្រី និងដាក់អន្ទាក់សត្វជាដើម ។ ពិសេសជាងនេះទៅទៀត ប្រជាជនមានបំណងចង់រក្សាព្រៃនោះទុកសំរាប់កូនចៅជំនាន់ក្រោយរបស់ពួកគាត់ និងដើម្បីធ្វើអោយមានលំ នឹងបរិស្ថានក្នុងតំបន់មិនអោយមានភាពប្រែប្រួលខ្លាំងពេក ដែលវានឹងនាំអោយជីវភាពរបស់ពួកគាត់ ជួបប្រទះ នឹងការលំបាកនៅពេលអនាគត ។

**២៣៨.** ប៉ុន្តែ បន្ទាប់ពីបានស្តាប់ការពន្យល់អំពីទិសដៅអភិវឌ្ឍន៏ តាមគំរោងស្នើសុំដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន និងការបកស្រាយអោយពួកគាត់បានយល់អំពីអន្តរកម្មរវាងភាពក្រីក្រ និងសភាពមិនអំណោយផលរបស់ធនធានធម្មជាតិដែលពួកគាត់បានកំពុងនឹងបន្តអាស្រ័យក្នុងអនាគត ជាពិសេសអំពីគោលការណ៍ និងនិតិវិធីក្នុងការផ្តល់ដីសមទានសេដ្ឋកិច្ចដល់ក្រុមហ៊ុន និងផលប្រយោជន៏ដែលប្រជាពលរដ្ឋនឹងទទួលបានមកវិញពិសេសគឺគោលការណ៏កាត់ឆ្វៀលចេញនូវដីទាំងឡាយណាដែលពាក់ព័ន្ធជារបស់ប្រជាពលរដ្ឋ ដោយថែមទាំងមានរក្សាដែនដីបំរុងសំរាប់កំណើនចំនួនប្រជាជនក្នុងពេលអនាគត ។ វាលស្មៅសំរាប់គោក្របីប្រជាពលរដ្ឋដើរកស៊ីប្រជាជនរស់នៅភូមិដែលពាក់ពន្ធ័ទាំងអស់ មានសេចក្តីសោមនស្សរីករាយនឹងទទួលយក គំរោងអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្ម លើដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ដោយគាត់បានយល់អំពី ផលប៉ះពាល់ពហុវិជ្ជមានរបស់គំរោងអភិឌ្ឍន៏ ដែលអាចនាំមកនូវការកែលំអ-លើកកំពស់ កំរិតជីវភាពរបស់ ប្រជាជនក្នុង សហគមន៏ តាមរយៈការផ្តល់នូវឱកាសការងារដល់យុវជន-យុវនារី ឬសមាជិក គ្រួសារដែលអាច បំរើការអោយគំរោងអភិវឌ្ឍន៍នេះបានរួមចំណែកក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន-ពង្រឹងប្រព័ន្ធសេវា សាធារណៈរបស់ស្រុក (ផ្លូវលំជនបទ សេវាកម្ម សុខភាព អណ្តូងទឹកស្អាត សាលារៀន) ពង្រឹងនិងពង្រីក ទំនាក់ទំនងអោយកាន់តែទូលាយរវាងសហគមន៏មូលដ្ឋានជាមួយនិងសង្គមខាងក្រៅ ដែលជំរុញអោយមានអន្តរ កម្មវិជ្ជមានទៅលើចរន្តសេដ្ឋកិច្ចសហគមន៏តាមរយៈការកើនឡើងនូវសេចក្តីត្រូវការ និងការផ្គត់ផ្គង់ទទូចហើយ ទទូចទៀត ។ សំណូមពរធ្វើយ៉ាងណាកុំឱ្យបាត់បង់ឬប៉ះពាល់ដល់ផលប្រយោជន៏ប្រជាពលរដ្ឋ ហើយរក្សាព្រៃ ដែនបំរុងសំរាប់គោ ក្របី ព្រៃបំរុងទុកសំរាប់កូនចៅជំនាន់ក្រោយរបស់ពួកគាត់ និងពិសេសគឺជួយធ្វើការ អភិវឌ្ឍន៏ ភូមិឃុំរបស់គាត់ផង ។

Draft

**២៣៩.** ក្នុងឱកាសចូលរួមពិគ្រោះយោបល់ តំណាងអោយប្រជាជនក្នុងសហគមន៏ទាំងមូល បានមានមតិ និងសំណូមពរដូចខាងក្រោម :

- លោក **មួង ធី** អភិបាលរងស្រុកឱរ៉ាល់ : ចំពោះបញ្ហាគំរោងអភិវឌ្ឍន៏នេះ ខ្ញុំសូមឯកភាពទាំងស្រុងតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលលោកជានិច្ចជាកាល តែងតែយកចិត្តទុកដាក់ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋកម្ពុជាយើង ។ ខ្ញុំសូមទទួលស្វាគមន៏ក្រុមហ៊ុនវិនិយោគ ដែលមានបំណងចូលមកធ្វើការអភិវឌ្ឍន៏លើដំណាំកសិឧស្សាហកម្ម នៅក្នុងទឹកដីស្រុកឱរ៉ាល់យើងខ្ញុំនេះ ។ ប៉ុន្តែក្រុមហ៊ុន

ត្រូវតែធ្វើការសម្របសម្រួលជាមួយប្រជាពលរដ្ឋចំពោះ ដីដែលមានការ ពាក់ពន្ធ័ផ្សេងៗ ដូចជាដីស្រែចំការ និងដីលំនៅស្ថានតាមបណ្តោយផ្លូវលេខ៩២ និងដីស្របតាមបណ្តោយអូរតោង។ កន្លងមក ក៏ដូចជាបច្ចុប្បន្នរវាងក្រុមហ៊ុន និងប្រជាពលរដ្ឋមានបញ្ហាមិនចុះសំរុងគ្នាខ្លះដែរ ដោយសារយើងមិនទាន់មានបទពិសោធន៏ ក្នុងការចុះទៅអនុវត្តគំរោងដំបូង ព្រោះចំណុចប៉ះពាល់ខ្លះយើងគិតស្មានមិន ដល់ធ្វើឱ្យមានការឆកប្រហោង។ ដំបូងមានក្រុមការងារអន្តរ ក្រសួង (កសិកម្ម រដ្ឋបាលព្រៃឈើ បរិស្ថាន រៀបចំដែនដី នគូរូបនីយកម្ម និងអាជ្ញាធរមូលដ្ឋាន) សហការជាមួយក្រុមការងារខេត្តចុះទៅស្រាវជ្រាវដោយកាន់ផែនទីចុច GPS ហើយសិក្សាវាយ តម្លៃផលប៉ះពាល់ទាំងអស់។ បានទិន្នន័យអស់ហើយយើងធ្វើរបាយការណ៍ ដាក់ជូនរាជរដ្ឋាភិបាល ទើបរាជរដ្ឋាភិបាលចេញអាជ្ញាបណ្ណ ដូច្នេះសព្វថ្ងៃក្នុងស្រុករបស់ខ្ញុំឃើញថាមានច្រើន ក្រុមហ៊ុន ហើយ ទាំងតូចទាំងធំ។ កន្លងមកមានប្រជាជនមួយចំនួនពួកគាត់មិនយល់ព្រមទាល់តែសោះ ទោះបីជា យើងចុះទៅដោះស្រាយពន្យល់គាត់ស្ទើររាល់ថ្ងៃក៏ដោយក៏គាត់មិនព្រមស្តាប់យើងដែរគាត់ជឿតែអ្នក ឆ្កឹះឆ្កៀលឯណោះទៅវិញ។ ជាលទ្ធផលសព្វថ្ងៃដំណើរការអនុវត្តន៏គំរោងរបស់ក្រុមហ៊ុនគឺស្ទះមិនអាចធ្វើតទៅទៀតកើត។ ជាសំណូមពរ ខ្ញុំសូមឱ្យក្រុមហ៊ុនជួយអភិវឌ្ឍន៏នៅមូលដ្ឋាននោះ នូវអ្វីដែលជាតំរូវការរបស់ប្រជា ពលរដ្ឋ ដូចជាផ្លូវគមនាគមន៏ ស្ពានព្រោះនៅតាមបណ្តោយភូមិមួយចំនួនមានការពិបាកក្នុងការធ្វើដំណើរណាស់ ពិសេសគឺនៅរដូវវស្សា។ ក្រៅពីនេះនៅមានខ្វះខាតសាលារៀន ប៉ុស្តិ៍សុខភាព អណ្តូងទឹកនិងអ្វីៗផ្សេងៗ ទៀត ដូច្នេះសូមក្រុមហ៊ុនជួយដល់សហគមន៏យើងខ្ញុំផង។

- លោក **រំណែម វ៉ាន់** អនុការិយាល័យកសិកម្មស្រុកឱរ៉ាល់: ខ្ញុំបានចុះទៅសិក្សាផលប៉ះពាល់របស់ក្រុមហ៊ុននោះនៅឃុំត្រពាំងជោ និងតំបន់ឆ្អិន តាមរយៈការចុះសក្សិា ឃើញថាមានបីចំណុច (១) បឹងច្រកស្លា (២)ស្រែសមុទ្រ និង(៣)បឹងក្របីងាប់ ដីទាំងអស់នេះជាដីអាស្រ័យ ផលរបស់ប្រជាពលរដ្ឋពិតប្រាកដ នៅពេលដែលចុះទៅឃើញក្រុមហ៊ុនបានឈូសប៉ះដល់ដីប្រជាពលរដ្ឋ ប៉ុន្តែ មិនមានប៉ះពាល់ដល់ដីស្រែរបស់ពួកគាត់ទេ។ ចំពោះដីត្រង់ចំណុចបឹងក្របីងាប់ និងបឹងតាមុំដែលស្ថិតនៅជិតការិយាល័យរបស់ក្រុមហ៊ុនបោះទីតាំង ហើយមួយទៀតបឹងគោលខ្ញុំបានពិភាក្សាជាមួយគណៈកម្មការចុះទៅ ពិនិត្យគួរតែកាត់ដីបឹងនេះចេញសំរាប់ទុកអោយប្រជាពលរដ្ឋប្រើប្រាស់មានផ្ទៃដីប្រហែល៥ហិកតា។ ចំណែកឯដីឃុំសង្កែសាទប ក្រុមការងារបានចុះសិក្សាអោយបានជិតដល់ទៅនៅពីក្រោយដីក្រុមហ៊ុនមានបឹងរវៀងដែល ឧបត្ថមដោយអង្គការ LWF ហើយបឹងនេះនៅតាមជ្រលង់បើយើងមើលទៅមិនសំរាប់អាស្រ័យផលទេ ប៉ុន្តែ បើយើងចុះអោយជិតដល់គាត់អាស្រ័យផលលើបឹងនេះ។ រីឯនៅតំបន់ឆ្អិនក្រុមការងារបានចុះទៅដល់បឹងពុទ្រា បឹងតាណឹល និងបឹងកោះដូនី្ត បើតាមលោកនាយកដែនជំរកថាបានកាត់ចេញអស់

Draft

ហើយមិនប៉ះពាល់អីទេ នៅក្នុង ស្រុកឱរ៉ាល់នេះ ប្រជាពលរដ្ឋបានចូលរួមចិញ្ចឹមសត្វគោច្រើនណាស់ នៅពេលបច្ចុប្បន្នតាមទំលាប់គាត់ប្រលែងចោល ដល់ខែបង្កបង្កើនផលទើបទៅចាប់យកទៅភូ្ល ចំពោះការធ្វើស្រែប្រជាពលរដ្ឋនៅឱរ៉ាល់មិនទំលាប់បើ ជីគីមីទេ គាត់ប្រើប្រាស់លាមកសត្វជំនួសជីគីមី ហើយធ្វើនៅតាមជ្រលង់អូរ និងស្ទឹង។ ខ្ញុំសូមសំណូរទៅក្រុមហ៊ុន កុំអោយកាយព្រំនៅតំបន់កោដ្ឋី ទុកអោយទឹកហូរ ពីទួលមកចូលស្រែពួកគាត់ផង យើងដឹងហើយនៅស្រុក ឱរ៉ាល់នេះជាតំបន់ខ្ពង់រាបអត់មានប្រភពទឹកទេ ការដាំដុះស្រោចស្រពគឺពឹងទៅលើទួលទាំងស្រុង សំរាប់ខ្ញុំ ស្វាគមន៍ក្រុមហ៊ុនដែលចូលមកវិនិយោគនៅស្រុកឱរ៉ាល់ ព្រោះបើគ្មានការវិនិយោគគ្មានការរីកចំរើន។

- លោក **ទេព រំណោម** មេឃុំត្រពាំងជោ ៖ ខ្ញុំមានការត្រេកអរចំពោះគំរោងអភិវឌ្ឍន៍ដែលនឹងរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនមូលដ្ឋាន តាមរយៈការបង្កើតមុខរបរ ក៏ដូចជាការផ្តល់ការងារធ្វើ ការធ្វើផ្លូវដើម្បីជួយសំរួលដល់ការ ធ្វើដំណើរ ធ្វើទំបន់ ជីកប្រឡាយ ធ្វើស្រះទឹក ការល្អសំរាប់ប្រជាពលរដ្ឋ។ ទន្ទឹមនឹងនេះក៏មានការខ្វល់ខ្វាយ និងព្រួយបារម្ភចំពោះដីស្រែដែលប្រជាពលរដ្ឋធ្លាប់ធ្វើកន្លងមក ក្នុងនោះមានភូមិមួយចំនួនធំមានការពាក់ពន្ធ័ ព្រោះពេលក្រុមហ៊ុនមកវិនិយោគអាចនឹងមានការប៉ះពាល់ដល់ដីស្រែដែលមាន។ ក្រោយមកថ្នាក់ដឹកនាំស្រុកបានបង្កើតគណៈកម្មការមួយចុះទៅពិនិត្យដីប៉ះពាល់ និងធ្វើការចុះយកចំណុចនិយាមកា ប៉ុន្តែនៅពេលដែលក្រុមហ៊ុនឈូសគាត់ឈូសខុសកន្លែងដែលក្រុមការងារចុះ (១) ត្រង់ចំណុចបឹងតាសុខ បើសិនក្រុមហ៊ុនឈូសទៅតាមចំណុចនិយាមកាដែលកំណត់ដោយក្រុមការងារគឺ អត់មានបញ្ហាអ្វីទាំងអស់ ក្រុមការងារកំណត់ពីខាងកើតគាត់មកឈូសខាងលិចទើបធ្វើអោយមានការប៉ះពាល់ (២) ដីនៅតំបន់គោលពីគោលទៅជើងប្រហែលជា១៤០ហិកតាប៉ុណ្ណោះ សូមកាត់ដីហ្នឹងចេញអោយផុតទុក សំរាប់ប្រជាពលរដ្ឋឃ្វាលគោ-ក្របី។ ខ្ញុំសូមសំណូមពរដល់អង្គប្រជុំជួយធ្វើអន្តរាគមន៍ជាមួយក្រុមហ៊ុនអោយធ្វើ ទៅតាមកិច្ចសន្យា និងធ្វើទៅតាមក្រុមការងារដែលចុះទៅពិនិត្យទាំងអស់គ្នាមានដូចជា៖ សហគមន៍ព្រៃឈើ តំណាងក្រុមហ៊ុន និងជំនាញពាក់ព័ន្ធទាំងអស់ ធ្វើយ៉ាងណាកុំអោយមានភាពល្អក់កករជា មួយប្រជាពលរដ្ឋ ។ ចំពោះខ្ញុំសូមស្វាគមន៍ក្រុមហ៊ុន **HLH AGRICULTURE (CAMBODIA) Co., Ltd.** ព្រោះកន្លងនៅក្នុង ស្រុកឱរ៉ាល់គ្រាន់តែមានដីក្រុមហ៊ុនទេតែអត់មានការអនុវត្តន៍ ចំណែកឯក្រុមហ៊ុននេះពេលបានសិទ្ធភ្លាមចាប់ផ្តើម ឈូសឆាយដាំដំណាំពេញទឹកពេញដីតែម្តង នេះជាលក្ខណៈមួយធ្វើអោយខ្ញុំមានទំនុកចិត្តណាស់។

- លោក **ណន សារុន** មេឃុំសង្កែសាទប ៖ ខ្ញុំសូមគោរពអភិបាលរងស្រុក និងសមាជិកនៃអង្គប្រជុំ ខ្ញុំសូមឯកភាពមតិរបស់លោកប្រធានការិយាល័យ កសិកម្មគាត់បានបញ្ជាក់ពីបញ្ហាផលប៉ះពាល់ ចំពោះឃុំ

Draft

ខ្ញុំអត់មានប៉ះពាល់ដីព្រៃសហគមន៍ទេ ផលប៉ះពាល់ រាល់ថ្ងៃទៅលើដីស្រែ និងដីចំការរបស់ប្រជាពលរដ្ឋ ដែលគាត់បំរុងទុកអោយកូនចៅជំនាន់ក្រោយ។ ខ្ញុំសូមឯកភាព ក្រុមហ៊ុនដែលមកវិនិយោគនៅក្នុងស្រុក ឱរ៉ាល់ ប៉ុន្តែបញ្ហាកន្លងមកដូចលោកមេឃុំត្រពាំងជោមានប្រសាសន៍ ក្រុមហ៊ុនធ្វើផ្ទុយពីកិច្ចសន្យា កន្លង ឃុំសង្កែសាទបមានប៉ះពាល់នៅត្រង់ភូមិដំបងវេញ បឹងក្រាំងគ្រួច និងបឹងក្រហាមករ នៅពេលដែល ក្រុមហ៊ុនឈូសឆាយមកឃើញថាប្រជាពលរដ្ឋមានការភ្ញាក់ផ្អើលថា ស្រុក ភូមិ លក់ដី អោយទៅក្រុមហ៊ុន។ ក្រោយមកស្រុកបានបង្កើតគណៈកម្មការចំរុះដើម្បីចុះសិក្សាប៉ះពាល់ឃើញថា ឃុំខ្ញុំក្រុមហ៊ុន សម្បទានអោយ ជាង២០០ ហិកតា ត្រង់ចំណុចបឹងក្រហាមកក ក្រាំងគ្រួច និងដំបងវេញ ក្រោយពីសិក្សាបាញ់ថ្នាំរួច ក្រុមហ៊ុននៅតែឈូសឆាយត្រង់ចំណុចនឹងធ្វើអោយប្រជាពលរដ្ឋរត់រកឃុំ អោយជួយទាំងទឹកភ្នែក ក៏ ប៉ុន្តែក្រុមហ៊ុន អត់ទាន់បានដាំដុះទេ។ ខ្ញុំសូមសំណូមពរក្រុមហ៊ុនថា កន្លែងណាដែលគណៈកម្មការបាន វាស់វែងហើយធ្វើយ៉ាងណា កុំអោយក្រុមហ៊ុនឈូសច្រឡំ សូមអោយមានការយោគយល់ដល់ប្រជាពលរដ្ឋ ព្រោះថានៅតំបន់នេះដីពួកគាត់ តាំងពីដើម បើសិនជាក្រុមហ៊ុនកាត់ទុកអោយប្រជាពលរដ្ឋបន្តិចទៀត ប្រហែលជាមានការងាយស្រួលច្រើន។

- លោក **ខុន ខេន** មេភូមិតាដែស ឃុំត្រពាំងជោៈ ដោយគំរោងវិនិយោគរបស់ក្រុមហ៊ុន HLH AGRICULTURE(CAMBODIA) CO.,Ltd. មានផលប៉ះពាល់ដល់ដីស្រែចំការរបស់ក្នុងភូមិតាដែស មុនក្រុមហ៊ុនចូលមកវិនិយោគ ក្រុមហ៊ុនបានសន្យានឹងធ្វើផ្លូវអោយចូលដល់ដីស្រែរបស់ពួកគាត់ ប៉ុន្តែ ប្រជាពលរដ្ឋចង់អោយក្រុមហ៊ុន កាត់ដីស្រែចំការត្រង់ចំណុចពីក្រសាំងទូករហូតទល់ក្រហាមករ អោយផុត ចេញពីក្រុមហ៊ុនតែម្តង។ សូមសំណូមពរទៅក្រុមហ៊ុនក៏ដូចជារដ្ឋាភិបាលជួយសាងសង់ ហេដ្ឋារចនាសម្ព័ន្ធ ដូចជាៈ អណ្តូងទឹក ផ្លូវ សាលារៀន ......។ល។ ដើម្បីអោយប្រជាពលរដ្ឋក្នុងមូលដ្ឋាន បានប្រើប្រាស់ ចំណែកដីដែលពាក់ព័ន្ធនឹងដីស្រែចំការរបស់ប្រជាពលរដ្ឋកំពុងបង្កបង្កើនផលបច្ចុប្បន្ន ត្រូវកាត់ចេញទុក អោយពួកគាត់។

- លោក **ទេស ភឿង** មេភូមិកន្ទួត ឃុំសង្កែសាទបៈ ប្រជាជនតែងមានការព្រួយបារម្ភពេល ដែលមានក្រុមហ៊ុន ស្នើសុំដីសំរាប់វិនិយោគ ខ្លាចមានការប៉ះពាល់ដល់ដីសំរាប់ធ្វើស្រែចំការ និងវាលស្មៅ សំរាប់គោ-ក្របីជាដើម ដូច្នេះដើម្បីអោយក្រុមហ៊ុនដំណើរការទៅមុខយ៉ាងរលូន ធ្វើយ៉ាងណាកុំ អោយការវិនិយោគប៉ះពាល់ដល់ដីស្រែ និងផលប្រយោជន៍របស់ប្រជាជន។ សំណូមពរទៅរដ្ឋាភិបាល ក៏ដូចជាក្រុមហ៊ុនសូមរក្សាទុកដីមួយចំនួន សំរាប់ដោះស្រាយដល់គ្រួសារដែលខ្វះខាតដីពិតប្រាកដ ចំណែក ដីដែលពាក់ពន្ធ័នឹងដីស្រែចំការរបស់ប្រជាពលរដ្ឋកំពុងបង្កបង្កើនផលបច្ចុប្បន្ន ត្រូវតែធ្វើ

Draft

ការកាត់ចេញ ហើយក៏សូមអោយរក្សាទុកដីបំរុងទុកសំរាប់ប្រើប្រាស់ជាប្រយោជន៍រួម ដល់សហគមន៍ (ថ្នាំឱសថបុរាណ ជាអុស និងជា វាលស្មៅសំរាប់គោ-ក្របី) ។

- លោក **ខែម ម៉ៅ** មេភូមិក្បាលដំរី ឃុំត្រពាំងៈ ចំពោះដីដែលក្រុមហ៊ុន HLH AGRICULTURE ស៊ីវិនិយោគនេះមានការប៉ះពាល់ដល់ដីដែលប្រជាជនបង្កបង្កើនមួយចំនួន។ សំណូមពរទៅ រាជរដ្ឋាភិបាល ជួយកាត់ដីស្រែចំការដែលពាក់ព័ន្ធជាមួយប្រជាជនដែលបានធ្វើតាំង១៩៨៦ ដែលសុទ្ធសឹងជាដីស្រែ ចាស់របស់គាត់ហើយត្រូវបោះបង់ក្នុងកំឡុងសង្គ្រាម ។ ក្រុមហ៊ុនគួរទុកដីព្រៃសំរាប់សហគមន៍អោយ ប្រជាពលរដ្ឋប្រើប្រាស់ ក៏ដូចជាគិតគូរដល់កូនចៅជំនាន់ក្រោយ ដែលកាន់តែកើនឡើងជារៀង រាល់ថ្ងៃ។ ជាការពិតណាស់ក្នុងនាមខ្ញុំតំណាង ប្រជាជនភូមិក្បាលដំរីមានការត្រេកអរចំពោះ ក្រុមហ៊ុនដែលចង់ចូលមកវិនិយោគនេះ ព្រោះវាអាចធ្វើអោយជីវភាពប្រជាជននៅក្នុងតំបន់មាន ភាពប្រសើរឡើងតាមរយៈ ការផ្តល់ការងារធ្វើដោយផ្តល់កំរៃសមរម្យ ជាពិសេសប្រជាជនអាច នឹងទទួលបាននូវបច្ចេកទេសថ្មីៗ ក្នុងការធ្វើកសិកម្មពីក្រុមហ៊ុនទៀតផង។ ជាសរុបមកខ្ញុំ សំណូមពរអោយក្រុមហ៊ុនរក្សាទុកដីអោយបាន ១-២ គីឡូម៉ែត្រ ដើម្បីអោយប្រជាជនអាច ធ្វើចំការ និងឃ្វាលគោក្របីបាន។

- លោក **ទួន ជុន** ប្រជាជនភូមិចំបក់ : ខ្ញុំចង់បានណាស់ក្រុមហ៊ុដែលចង់វិនិយោគនៅតំបន់នេះទេ បើក្រុមហ៊ុនវិនិយោគ បណ្តាលអោយបាត់បង់ព្រៃឈើដែលតែងតែទាញយកផល-អនុផលព្រៃឈើ កន្លងមក នោះនឹងធ្វើអោយមានការប៉ះពាល់ដល់ជីវភាពប្រជាជនមិនខាន តែបើសិនជារដ្ឋ ចាំបាច់ត្រូវការយកដីប្រគល់ឱ្យក្រុមហ៊ុនហើយ សំណូមពរសុំអោយនៅឆ្ងាយពីភូមិដើម្បីអោយ ផុតដីស្រែចំការប្រជាជន។ បើសិនមានការប៉ះពាល់ដល់ដីរបស់ប្រជាជនសុំធ្វើការដោះស្រាយឱ្យ ប្រជាជនអោយបានសមស្រប ព្រោះជាដីស្រែចាស់ដែលប្រជាជនបានបោះបង់ចោលដោយសារតែសង្គ្រាម ក្រោយមកប្រជាជនបានត្រឡប់មកកាន់កាប់ និងធ្វើស្រែឡើងវិញតាំងពីឆ្នាំ ១៩៨៦-៨៧ មកម្លេះ និងសូមកាត់ដីព្រៃសហគមន៍ចំនួន២៨៥១ ហិកតា ដែលបង្កើតឡើងនៅថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០០៥ ដោយក្រសួងបរិស្ថានចេញពីតំបន់វិនិយោគ។ លើសពីនេះទៅទៀត សុំឱ្យក្រុមហ៊ុនចូលរួមអភិវឌ្ឍន៍សហគមន៍នូវហេដ្ឋារចនាសម្ព័ន្ធ ផ្សេងៗដែលរួមមាន ជួយធ្វើផ្លូវ សាលារៀន អន្លូងទឹក ប្រឡាយទឹក សំរាប់បង្កបង្កើនផលស្រែចំការជាដើម ។

- អ៊ុំស្រី **ពុទ្ធ ឡា** ប្រជាជនភូមិកោដូន្តី : ជាការពិតហើយការអភិវឌ្ឍន៍តែងតែមានការប៉ះពាល់តិចឬច្រើនគឺជៀសមិនផុតឡើយ ដូចនេះសុំធ្វើយ៉ាងណាឱ្យការប៉ះពាល់ទាំងនោះមានទំហំតិចតួច ដែលអាចឱ្យប្រជាជន នៅក្នុងតំបន់អភិវឌ្ឍន៍អាចទទួលយកទាំងអស់គ្នាទាំងក្រុមហ៊ុន ទាំងប្រជាពលរដ្ឋ។ អ្វីដែលខ្ញុំមានការព្រួយបារម្ភបំផុតនោះ ការដែលក្រុមហ៊ុនវិនិយោគប៉ះទៅលើ ដីព្រៃសហគមន៍ដែល

ពួកគាត់តែងតែរុករកអនុផលព្រៃ ព្រោះប្រជាពលរដ្ឋពួកគាត់ជាជនជាតិ ភាគតិចគ្មានអ្វីក្រៅពីចូលព្រៃកាប់ឈើដើម្បីចិញ្ចឹមជីវិត ដូច្នេះសូមអោយក្រុមហ៊ុនដែលចូលមក វិនិយោគនៅតំបន់នេះ គិតគូរដល់ប្រជាពលរដ្ឋជនជាតិពួកគាត់ដែលរស់នៅពឹងអាស្រ័យតែទៅលើព្រៃឈើ ។ ខ្ញុំសូមសំណូមពរទៅរដ្ឋាភិបាលនិងក្រុមហ៊ុន HLH AGRICULTURE សូមកាត់ ដីព្រៃសហគមន៍ចេញពីតំបន់វិនិយោគរបស់ក្រុមហ៊ុន ។

- បងស្រី **ពៅង រី** ប្រជាជនភូមិត្រាងះ បើសិនជាក្រុមហ៊ុន និងថ្នាក់លើបានដោះស្រាយដីដែលប៉ះពាល់ដីប្រជាជន ឬកាត់ទុកអោយគាត់វិញនោះវាមិនមានបញ្ហាអ្វីទេ។ ម្យ៉ាងទៀតសូម ក្រុមហ៊ុនកំណត់ព្រំប្រទល់ដីដែលវិនិយោគអោយបានច្បាស់លាស់ ជាសវៀងមានការប៉ះពាល់ទង្គិចគ្នារវាងប្រជាពលរដ្ឋ និងក្រុមហ៊ុននៅថ្ងៃក្រោយ ។ សំណូរពរអោយក្រុមហ៊ុន និងរដ្ឋាភិបាល ក៏ដូចជាប្រជាជនដែលពាក់ព័ន្ធត្រូវមានទំនាក់ទំនងល្អ ដោះស្រាយដោយសន្តិវិធីជៀសវាងការ ប្រើកំលាំងការពារ មកទំនាស់ជាមួយប្រជាជនដែលទៅកាប់ឆ្ការ ។

- អ្នកមីង **ស៊ូក ហេង** ប្រជាពលរដ្ឋភូមិដំបងវេញ : ទីតាំងដែលក្រុមហ៊ុនស្នើសុំ មានការប៉ះពាល់ដល់ដីស្រែ របស់ប្រជាជនភូមិដំបងវេញ ដែលទីតាំងមានចំងាយប្រមាណ ២គីឡូម៉ែត្រពីភូមិ ។ សំណូមពរអោយក្រុមហ៊ុនរក្សាទុកចំងាយប្រមាណ ២០០ម៉ែត្រពីស្រែចំការរបស់ពួកគាត់ នឹងត្រង់ចំណុចចាប់ពីវាលរវាំងរហូតដល់ត្រង់តំបន់ក្រសាំង សូមទុកអោយពួកគាត់បង្កបង្កើនផល ។

- លោក **ខាត់ សុខៀ** ប្រជាជនភូមិច្រកទៀកៈ ខ្ញុំមានការរីករាយដែលមានក្រុមហ៊ុនចូលមកវិនិយោគនៅក្នុងភូមិឃុំ ប៉ុន្តែការដែលបារម្ភចំពោះមុខក្រុមហ៊ុនបានធ្វើការឈូសឆាយព្រំប៉ះពាល់ លើដីស្រែចំការដែលប្រជាពលរដ្ឋបង្កបង្កើតផល និងកន្លែងដែលពួកគាត់ធ្លាប់លែងគោ-ក្របី អោយស៊ីស្មៅ ។ ខ្ញុំសូមសំណូមពរទៅរដ្ឋាភិបាលក៏ដូចជាក្រុមហ៊ុនដោះស្រាយដីដែលពាក់ព័ន្ធនឹង ប្រជាពលរដ្ឋអោយបានដាច់ស្រឡះសិន មុននឹងធ្វើការវិនិយោគ ជាសវៀងមានបញ្ហាកើតឡើង ថ្ងៃក្រោយ ។

Draft